វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ទីស្តីការគណៈរដ្ឋមន្ត្រី
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សង្ខេបសម្រាប់ គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០៩

# តួនាទីនៃពិពិធកម្មប្រភពចំណូលក្នុងពេលមាន វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាកល

*បណ្ឌិត តុង គឹមស៊ុន និង កញ្ញា ផៃ សុខចេង*[១]

## សេចក្តីផ្តើម

នៅចុងទសវត្សរ៍កន្លងទៅនេះ កម្ពុជាបានទទួលរងការប៉ះទង្គិចពីវិបត្តិសេដ្ឋកិច្ចធំៗពីរ គឺការឡើងថ្លៃប្រេងឥន្ធនៈនិងអាហារ និងវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសាកល។ កំណើនថ្លៃអាហារនិងប្រេងឥន្ធនៈយ៉ាងខ្ពស់មិនធ្លាប់ជួបនៅឆ្នាំ២០០៨ ជាការប៉ះទង្គិចពីខាងក្រៅដ៏ធ្ងន់ធ្ងរបំផុតមួយដល់កម្ពុជា។ ហើយនៅតាមក្រោយនោះ វិបត្តិហិរញ្ញវត្ថុសាកល បានប៉ះទង្គិចមកលើប្រទេសកម្ពុជានៅឆ្នាំ២០០៩ ធ្វើឲ្យស្ថានភាពដ៏លំបាកស្រាប់ កាន់តែយ៉ាប់យ៉ឺនថែមទៀត ជាពិសេសសម្រាប់អ្នកក្រីក្រ និងក្រុមជនងាយរងគ្រោះ។ ការសិក្សាមួយចំនួនក្នុងពេលកន្លងមកបង្ហាញថាវិបត្តិបានប៉ះពាល់ខ្លាំងជាងគេទៅលើអ្នកក្រ និងជនងាយរងគ្រោះ ដោយជាសំខាន់មកពីភាពទន់ខ្សោយនៃយុទ្ធសាស្ត្រជាផ្លូវការ សម្រាប់ទប់ទល់នៅមុនពេល និងក្រោយពេលមានវិបត្តិ ភាពទន់ខ្សោយនៃប្រព័ន្ធធានារ៉ាប់រងសង្គមមិនផ្លូវការ ព្រមទាំងកង្វះចម្លើយតបជាសាធារណៈ (e.g Tong *et al.* 2009; Tong 2010; Chan & Ngo 2010)។ ឆ្លងតាមការពិនិត្យស្រាវជ្រាវសព្វគ្រប់ យើងដឹងថា នៅកម្ពុជាមិនទាន់មានធ្វើការសិក្សាណាមួយអំពី តួនាទីនៃពិពិធកម្មប្រភពចំណូលក្នុងពេលមានវិបត្តិនោះទេ ទោះបីនៅប្រទេសដទៃគេរកឃើញថាវាមានទំនាក់ទំនងវិជ្ជមានជាមួយនឹង ការបង្កើនទ្រព្យ និងការថយចុះភាពងាយរងគ្រោះ ឬក៏យ៉ាងហោចណាស់ វាបានជួយសម្រួលឲ្យ ចំណាយប្រើប្រាស់មានស្ថិរភាពមួយកម្រិត (Barrett *et al.* 2001; Kinsey *et al.* 1998)។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យអង្កេតតាមពេលវេលា លើប្រជាជន ៧៩៣គ្រួសារ ដែលវិទ្យាស្ថាន CDRI បានប្រមូលយកនៅឆ្នាំ ២០០១, ២០០៤-០៥, ២០០៨ និង ២០១១។ ប្រាក់ចំណូលគ្រួសារបានពីប្រភពផ្សេងៗ ដូចជា ផលដំណាំ សត្វចិញ្ចឹម ធនធានទ្រព្យរួម និងសកម្មភាពមិនមែនកសិកម្មផ្សេងៗ បានយកមកប្រើប្រាស់ដើម្បីបង្កើតសន្ទស្សន៍ពិពិធកម្មប្រភពចំណូល ពោលគឺសន្ទស្សន៍ Herfindahl។ សន្ទស្សន៍ Herfindahl គឺជាផលបូកនៃតួលេខទ្វេគុណនៃចំណែកនៃមុខចំណូលផ្សេងៗ នៅក្នុងប្រាក់ចំណូលគ្រួសារ៖ តួលេខសន្ទស្សន៍កាន់តែតូច មានន័យថាពិពិធកម្មប្រភពចំណូលមានកម្រិតកាន់តែខ្ពស់ (Dimova and Sen 2010)។ ការសិក្សានេះ បានប្រើទាំងវិធីសាស្ត្រពិពណ៌នា និងវិធីសាស្ត្រសេដ្ឋកិច្ចមាត្រសាស្ត្រ (descriptive and econometric methods) ដើម្បីពិនិត្យពីពិពិធកម្មប្រភពចំណូលក្នុងអំឡុងពេលមានវិបត្តិ។

## លទ្ធផលស្រាវជ្រាវ

មានការកត់សំគាល់ជាទូទៅថា គ្រួសារនៅជនបទទទួលបានប្រាក់ចំណូលពីប្រភពផ្សេងៗជាច្រើន។ ក្នុងការសិក្សានេះ ប្រាក់ចំណូលគ្រួសារចែកចេញជា ៣ ក្រុមធំៗ គឺចំណូលពីផលដំណាំ ចំណូលពីការចិញ្ចឹមសត្វ និងចំណូលពីសកម្មភាពមិនមែនកសិកម្ម។ ការសិក្សាបានរកឃើញថា ចំណូលក្នុងមនុស្សម្នាក់កើនយ៉ាងច្រើនដល់ ៧៥% ពីឆ្នាំ ២០០១ ដល់ ២០០៤ និង ៥២% នៅឆ្នាំ២០០៨ នៅមុនពេលធ្លាក់ចុះអស់ ២០ឯកតាភាគរយ នៅឆ្នាំ ២០១១ (តារាង ១)។ តួលេខនេះផ្តល់ជាគំនិតថា វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល អាចមានផលប៉ះពាល់អូសបន្លាយ យូរជាងមួយឆ្នាំទៅទៀត។ ចំណូលពីផលដំណាំក្នុងមនុស្សម្នាក់ កើន ៩៧% នៅឆ្នាំ២០០៤ និង ៧៩% នៅឆ្នាំ២០០៨ ប៉ុន្តែធ្លាក់ចុះអស់ ១០% នៅឆ្នាំ២០១១ ហើយចំណូលពីសត្វចិញ្ចឹម និងចំណូលពីសកម្មភាពមិនមែនកសិកម្មក្នុងមនុស្សម្នាក់ ធ្លាក់ចុះ ៣១% និង ២៧% ក្នុងពេលជាមួយគ្នា។ គួរកត់សំគាល់ថា គ្រួសារដែលធូរធារទំនងទទួលបានអត្ថប្រយោជន៍ច្រើនជាងគេ ពីកំណើនសេដ្ឋកិច្ចក្នុងកំឡុងឆ្នាំ២០០១-២០០៤ ហើយក៏ទទួលរងផលប៉ះពាល់តិច

[១] លោកបណ្ឌិត តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួល និង កញ្ញា ផៃ សុខចេង ជាជំនួយការស្រាវជ្រាវ នៃកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅវិទ្យាស្ថាន CDRI។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

តារាង ១៖ ចំណូលក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ បានពីប្រភពផ្សេងៗ

| | ចំណូលក្នុងមនុស្សម្នាក់គិតតាមថ្លៃថេរឆ្នាំ២០១១ (ម៉ឺនរៀល) | | | | អត្រាកំណើន (%) | | |
|---|---|---|---|---|---|---|---|
| | 2001 | 2004 | 2008 | 2011 | 2004 | 2008 | 2011 |
| ផលដំណាំ | 15.59 | 30.67 | 55.01 | 49.66 | 96.73 | 79.36 | -9.73 |
| សត្វចិញ្ចឹម | 11.04 | 14.38 | 22.22 | 15.32 | 30.25 | 54.52 | -31.05 |
| សកម្មភាពមិនមែនកសិកម្ម | 20.45 | 37.38 | 48.40 | 35.18 | 82.79 | 29.48 | -27.31 |
| ចំណូលសរុប | 47.08 | 82.43 | 125.64 | 100.16 | 75.08 | 52.42 | -20.28 |

ប្រភព៖ ទិន្នន័យអង្កេតគ្រួសាររបស់វិទ្យាស្ថាន CDRI (២០០១-២០១១)

ជាងគេពីវិបត្តិដែរ។ ក្រុមអ្នកក្រីក្រជាងគេ ទំនងទទួលរងការប៉ះទង្គិចខ្លាំងជាងគេពីវិបត្តិ ព្រោះចំណូលក្នុងមនុស្សម្នាក់ក្នុងក្រុមនេះធ្លាក់ចុះអស់ ២៧,៦% ពីឆ្នាំ ២០០៨ ដល់ ២០១១។

ជាមធ្យម សន្ទស្សន៍ Herfindahl តែងតែកើនឡើងជាបន្តបន្ទាប់ ដែលបង្ហាញថា គ្រួសារនៅក្នុងភូមិជ្រើសរើសមកសិក្សា មានពិពិធកម្មប្រភពចំណូលកម្រិតទាបជាងកាលពី ១០ឆ្នាំមុន។ ដោយបានយកសន្ទស្សន៍ Herfindahl សម្រាប់ឆ្នាំនីមួយៗ ទៅធៀបនឹងចំណូលនៅឆ្នាំ២០០១ គ្រួសារក្នុងក្រុមបញ្ចភាគទី២ និងទី៣ ទំនងមានពិពិធកម្មប្រភពចំណូល ខ្ពស់ជាង គ្រួសារក្នុងក្រុមបញ្ចភាគទី១ ទី៤ និង ទី៥។ ម៉ូដែលសេដ្ឋកិច្ចមាត្រសាស្ត្រ (econometric model) ក្នុងការសិក្សានេះបានបង្ហាញថា បើសិនគ្រួសារមានសមាជិកជាបុរសពេញវ័យកាន់តែច្រើននាក់ កម្រិតពិពិធកម្មប្រភពចំណូលគ្រួសារនោះក៏កាន់តែខ្ពស់ដែរ។ គ្រួសារប្រកបរបរកសិកម្ម ទំនងចូលរួមបានច្រើនជាងក្នុងសកម្មភាពធ្វើពិពិធកម្ម។ ស្ថានភាពទ្រព្យសម្បត្តិ ដែលកំណត់ឡើងតាមសន្ទស្សន៍ទ្រព្យជាប់លាប់ និងការមានដីកសិកម្ម វាមានទំនាក់ទំនងជាវិជ្ជមាន ជាមួយនឹងការចូលរួមកម្រិតខ្ពស់ក្នុងការធ្វើពិពិធកម្ម។ គ្រួសារដែលធ្លាប់ជួបបញ្ហាខាងសុខភាព និងការខូចខាតផលដំណាំ តែងមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងយុទ្ធសាស្ត្រធ្វើពិពិធកម្ម។ សកម្មភាពធ្វើពិពិធកម្មប្រភពចំណូលមានឥទ្ធិពលជួយកាត់បន្ថយភាពក្រីក្រ ប៉ុន្តែមិនទំនងដើរតួនាទីជាយុទ្ធសាស្ត្រទប់ទល់ជាមុន ដ៏មានប្រសិទ្ធភាព ក្នុងអំឡុងពេលមានការប៉ះទង្គិចពីខាងក្រៅ ដូចជា វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាកលនោះទេ។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះរកឃើញថា គ្រួសារនៅក្នុងភូមិបានជ្រើសរើសមកសិក្សា មានកម្រិតធ្វើពិពិធកម្មតិចជាងកាលពី ១០ឆ្នាំមុន។ ចំណូលពីផលដំណាំ ទទួលរងការប៉ះពាល់តិចជាងគេ ពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ហើយបានក្លាយជាប្រភពចំណូលចម្បងសម្រាប់គ្រួសារនៅជនបទ។ ចំនួនសមាជិកគ្រួសារជាបុរសមានអាយុ ១៥-៦៤ឆ្នាំ មេគ្រួសារប្រកបរបរកសិកម្ម ទ្រព្យជាប់លាប់ ការមានដីកសិកម្ម បញ្ហាខាងសុខភាព និងការខូចខាតផលដំណាំ គឺជាកត្តាកំណត់ដ៏សំខាន់នៃពិពិធកម្មប្រភពចំណូលនៅតាមជនបទកម្ពុជា។ ពិពិធកម្មប្រភពចំណូលមានទំនាក់ទំនងយ៉ាងខ្លាំង និងជាវិជ្ជមាន ជាមួយនឹងចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ប៉ុន្តែមិនទំនងជាអាចជួយសម្រួលដល់ចំណាយប្រើប្រាស់ក្នុងអំឡុងពេលមានវិបត្តិទេ។ លទ្ធផលរកឃើញទាំងនេះ បានបញ្ជាក់ថែមទៀតពីតម្រូវការនូវការផ្តល់ប្រព័ន្ធសុវត្ថិភាពដ៏ល្អមួយ សម្រាប់ធ្វើជាយុទ្ធសាស្ត្រជួយកាត់បន្ថយហានិភ័យ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាល និងអង្គការពាក់ព័ន្ធនានាគួរជំរុញសកម្មភាពមិនមែនកសិកម្មផ្សេងៗ ព្រោះវាដើរតួនាទីសំខាន់ក្នុងការកែលំអចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ និងអនុបាតភាពក្រីក្រ ពីមួយឆ្នាំទៅមួយឆ្នាំ។